ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ
លេខ........................................

# របាយការណ៍

## បូកសរុបលទ្ធផលការងារប្រចាំខែកុម្ភៈ ឆ្នាំ២០២២

**ក-អំពីកម្លាំង៖**

សរុបបួមចំនួន៖ ០៥នាក់ (ស្រី០២នាក់) អវត្តមាន៖ ០០

**ខ-សកម្មភាព និងលទ្ធផលការងារ**

ខ.១-កិច្ចប្រជុំពង្រឹងកិច្ចសហប្រតិបត្តិការ ការកសាងគោលនយោបាយ និងបទដ្ឋានគតិយុត្តិនានា

សកម្មភាពក្នុងស្រុក

- **ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង បានអញ្ជើញចូលរួមកិច្ចប្រជុំពិនិត្យ កែសម្រួលខ្លឹមសាររបាយការណ៍ ឆ្នាំ២០២១ និងលើកទិសដៅ ឆ្នាំ២០២២ សម្រាប់ត្រៀមសន្និបាត ខែមិនា ឆ្នាំ២០២២ខាងមុខ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃនិងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ អញ្ជើញចូលរួមក្នុងកិច្ចប្រជុំនេះមាន លោកជំទាវ ឧ.ឯក វេជ្ជ. ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង ទទួលបន្ទុកក្រុមជំនួយកិច្ចការនិង ប្រធានក្រុមជំនួយកិច្ចការទាំង០៦ ក្រុមការងារបូកសរុបការងាររបាយការណ៍ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងមន្ត្រីពាក់ព័ន្ធនៃលេខាធិការដ្ឋាន រដ្ឋបាល-សរុប។

- **ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២** លោកស្រីវរសេនីយ៍ត្រី ថោង សុវត្ថិ បានអញ្ជើញចូលរួម ក្នុងយុទ្ធនាការគាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ីនធឺណិត ក្រោមប្រធានបទ «រួមគ្នាលើកកម្ពស់ ការពារ និងគោរពសិទ្ធិកុមារ តាមរយៈការប្រើប្រាស់ប្រព័ន្ធអនឡាញប្រកបដោយទំនួលខុសត្រូវ» ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃនិងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងក្រសួងអប់រំ យុវជន និងកីឡា បានសហការរៀបចំឡើងនៅវិទ្យាស្ថានជាតិអប់រំ ដោយមានការឧបត្ថម្ភគាំទ្រពីអង្គការ Aple Cambodia និងសហការឧបត្ថម្ភដោយ អង្គការ Plan International Cambodia អង្គការ UNICEF និងក្រុមហ៊ុន Smart Axiata ដែលមានការចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាល និងក្រុមហ៊ុនឯកជន ដូចជា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន

និងយុវនីតិសមប្បទា ក្រសួងវប្បធម៌ និងវិចិត្រសិល្ប ក្រសួងប្រៃសណីយ៍ និទូរគមនាគមន៍កម្ពុជា ក្រសួងយុត្តិធម៌ ក្រសួងធម្មការ និងសាសនា ក្រុមប្រឹក្សាជាតិដើម្បីកុមារ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា កងរាជអាវុធហត្ថលើផ្ទៃប្រទេស អង្គការក្រៅរដ្ឋាភិបាល ក្រុមហ៊ុនផ្តល់សេវាកម្មទូរស័ព្ទចល័ត លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សប្រមាណ ៣៥០នាក់។

- **ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង បានអញ្ជើញចូលរួមកិច្ចប្រជុំស្តីពីៈ ការធ្វើបទបង្ហាញពីសេវាកម្ម និងព័ត៌មាននៃគម្រោងមជ្ឈមណ្ឌល CASA ដែលស្នើឡើងដោយអង្គភាពការពារកុមារ CPU ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ។ អញ្ជើញចូលរួមមាន លោកជំទាវ ឧត្តមសេនីយ៍ឯក ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ លោក Scott Neeson ស្ថាបនិកនៃអង្គការមូលនិធិកុមារកម្ពុជា CCF, លោក James McCabe នាយកប្រតិបត្តិ នៃអង្គភាពការពារកុមារ CPU, លោក Mike Smith ប្រធានផ្នែកស៊ើបអង្កេត នៃអង្គភាពការពារកុមារ CPU, លោក Raymond Kirwan អ្នកជំនាញបច្ចេកទេសវិទ្យាសាស្ត្រ និងពេគវិជ្ជា នៃអង្គភាពការពារកុមារ CPU, លោក យាង សុខលាង អ្នកជំនាញផ្នែកកោសល្យវិច័យ នៃអង្គភាពការពារកុមារ CPU, លោក Nick Rose ប្រធានផ្នែក ICAC នៃអង្គភាពការពារកុមារ CPU, ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង ប្រធានលេខាធិការដ្ឋានរដ្ឋបាលសរុប ប្រធានក្រុមជំនួយកិច្ចការទាំង៦ និងក្រុមការងារបច្ចេកទេស នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។

- **ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង បានអញ្ជើញចូលរួមកម្មវិធីសិក្ខាសាលាថ្នាក់ជាតិស្តីពីៈ ការរៀបចំផែនការជាតិសម្រាប់អនុវត្តកតិកាសញ្ញាពិភពលោកស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ ដែលរៀបចំដោយអង្គការ IOM នៅសណ្ឋាគារកាំបូឌីយ៉ាណា ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ អញ្ជើញចូលរួមពី ឯកឧត្តម ហូ វុឌ្ឍី រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឯកឧត្តម កែ វិសិទ្ធិ អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឯកឧត្តម ម៉ៅ តាន់អ៊ាង អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល លោកជំទាវ ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ លោក គៀវ ខៃ ប្រធានគម្រោង អង្គការ IOM តំណាង លោកស្រី គ្រីស្ទីនផាកូ ឯកឧត្តម លោកជំទាវ លោក លោកស្រី អគ្គលេខាធិការរង អគ្គនាយករង ប្រធាន អនុប្រធាននាយកដ្ឋាន តំណាងក្រសួង ស្ថាប័ន អង្គការដៃគូពាក់ព័ន្ធ និងមន្ត្រីបច្ចេកទេសមួយចំនួនទៀត។

- **ថ្ងៃទី១៥-១៦ ខែកុម្ភៈ ឆ្នាំ២០២២** នាសាលប្រជុំផ្នែកបណ្តុះបណ្តាលបន្តមន្ទីរសុខាភិបាល ខេត្តបាត់ដំបង លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង ទទួលបន្ទុកក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ បានសហការរៀបចំ វគ្គបណ្តុះបណ្តាលស្តីពីៈ "កិច្ចការពារកុមារ និងការកំណត់អត្តសញ្ញាណជន

រងគ្រោះ ដោយអំពើជួញដូរមនុស្ស និងការរំលោភបំពាន - Training on Child Protection and Identification of Human Trafficking and Abuse” ដែលកម្មវិធីបើកវគ្គបណ្តុះបណ្តាលបានប្រព្រឹត្តិទៅក្រោមអធិបតីភាព លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងកម្មវិធីបិទវគ្គ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ លោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍គជបជ។ វគ្គបណ្តុះបណ្តាលនេះកើតឡើង ក្រោមកិច្ចសហការរវាង អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាមួយ ក្រសួងសុខាភិបាល ដោយមានជំនួយឧបត្ថម្ភពីសហភាពអឺរ៉ុប (EU) តាមរយៈ អង្គការយូនីសេហ្វ ក្នុងគោលបំណង ផ្សព្វផ្សាយឱ្យបានកាន់តែទូលំទូលាយ និងពង្រឹងសមត្ថភាព ជូនមន្ត្រីអនុវត្តផ្ទាល់នៅមូលដ្ឋាន សរុបចំនួន ៣៥រូប (ស្រី១១រូប) អញ្ជើញពី ស្រុកថ្មគោល ស្រុករតនៈមណ្ឌល នៃខេត្តបាត់ដំបង និងក្រុងសិរីសោភ័ណ ក្រុងប៉ោយប៉ែត ស្រុកម៉ាឡៃ ស្រុកស្វាយចេក និងស្រុកថ្មពួក នៃខេត្តបន្ទាយមានជ័យ ក្នុងចំណោមអ្នកចូលរួមសរុប ៤៥រូប (ស្រី១៩រូប) ក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះ ជាពិសេសស្ត្រី និងកុមារ ការបញ្ជូនករណីកុមាររងគ្រោះ និងងាយរងគ្រោះទៅកាន់សេវាសមស្រប ដើម្បីជានាការការពារ និងសុខមាលភាពរបស់កុមារដែលទទួលរងផលប៉ះពាល់ពីចំណាកស្រុក។ អញ្ជើញចូលរួមជាគ្រូឧទ្ទេសមាន លោកជំទាវ ឧត្តមសេនីយទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង លោកឧត្តមសេនីយត្រី អិុន មាន ប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិនិងអន្តរជាតិ លោកឧត្តមសេនីយ៍ទោ កែវ ផល្លា ប្រធានក្រុមជំនួយកិច្ចការយុត្តិធម៌, លោកស្រីវេជ្ជបណ្ឌិត តេង ស្រី អនុប្រធាននាយកដ្ឋានប្រយុទ្ធជំងឺឆ្លងនៃក្រសួងសុខាភិបាល លោកស្រី ចាន់ កញ្ញា មន្ត្រីកិច្ចការពារកុមារ លោក ភួង សិទ្ធី គ្រូបង្គោលសង្គមកិច្ចខេត្ត និង លោកស្រី ផន ចាន់វាសនា អ្នកប្រឹក្សាចិត្តសាស្ត្រ អង្គការ TPO និងសមាភាពចូលរួមមាន លោកជំទាវ ក្រុមប្រឹក្សាខេត្តបន្ទាយមានជ័យទទួលបន្ទុកកិច្ចការនារីនិងកុមារ លោកជំទាវអភិបាលរងនៃគណៈអភិបាលខេត្តបាត់ដំបង លោកជំទាវអភិបាលរងនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ប្រធានមន្ទីរពេទ្យស្រុក មណ្ឌលសុខភាពប្រតិបត្តិ អធិការរង មេបញ្ជាការរងមូលដ្ឋានកងរាជអាវុធហត្ថ ប្រធានការិយាល័យសង្គមកិច្ច នាយរងផ្នែកយុត្តិធម៌ អ.ហ អភិបាលរងក្រុង អភិបាលរងស្រុក ប្រធានមន្ទីរកិច្ចការនារី ប្រធានការិយាល័យកិច្ចការនារី ប្រធានការិយាល័យសង្គមកិច្ច អនុប្រធានមណ្ឌលចត្តាឡីស័ក មេបញ្ជាការរងវរៈព្រំដែន។

- **ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង បានអញ្ជើញចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពី៖ «ការកំណត់អត្តសញ្ញាណ ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប» ជាមួយរដ្ឋបាលខេត្តបាត់ដំបង។ សិក្ខាសាលានេះធ្វើឡើងក្រោមកិច្ចសហការរវាងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងលោក Mark Taylor ប្រធានគំរោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជានៃអង្គការ Winrock ដែលមានការអញ្ជើញចូលរួមជាសិក្ខាកាមមកពីស្រុកកំរៀង នៃខេត្តបាត់ដំបងរួមមាន ប្រធាន គ.ក.ស.ក អភិបាលរងស្រុក ឃុំ មន្ត្រីទទួលបន្ទុកកិច្ចការនារីឃុំ គ.ក.ន.ក នាយកសាលា សង្គមកិច្ចដែលមានសិក្ខាកាមចូលរួម ៣០នាក់។ វគ្គបណ្តុះបណ្តាលស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ មានគោលដៅជំរុញអនុវត្តគោលការណ៍ ណែនាំស្តីពីបែបបទ និងនីតិវិធីនៃការកំណត់ អត្តសញ្ញាណជនរងគ្រោះ

ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប។ ដើម្បីឱ្យជនរងគ្រោះទទួលបានសេវាបឋម ចាំបាច់បន្ទាន់ និងអាចបន្តជួយគាំទ្រផ្តល់កិច្ចការពារ តាមរយៈសេវាបញ្ជូន ទៅគោលដៅ ផ្តល់សេវា ជាក់លាក់។ វគ្គបណ្តុះបណ្តាលនេះផងដែរ ធ្វើឡើងក្នុងគោលបំណង ដើម្បីឱ្យអ្នកមានភារកិច្ច កំណត់អត្តសញ្ញាណជនរងគ្រោះយល់បានច្បាស់ ពីនីតិវិធី និងអាចប្រើប្រាស់ បែបបទដែលពាក់ព័ន្ធ ក្នុងដំណើរការនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ យល់ដឹងអំពី ច្បាប់ និងអាចសន្និដ្ឋានជាបឋម ដោយភាពប្រាកដប្រជា ដើម្បីទទួលបានលទ្ធផល និងពត៌មានត្រលប់ស្តីពី ការប្រើប្រាស់បទដ្ឋាននានា ភាពប្រឈម និងចំនុចខ្វះខាតនៃការ ណែនាំក្នុងការអនុវត្ត ដើម្បីកែលម្អ បង្កើនប្រសិទ្ធភាពការងារ ក្នុងការផ្តល់ សេវាបឋមជូនដល់ជនរងគ្រោះ។

- **ថ្ងៃទី១៧-១៨ ខែកុម្ភៈ ឆ្នាំ២០២២** នាសាលប្រជុំផ្នែកបណ្តុះបណ្តាលបន្តមន្ទីសុខាភិបាល ខេត្តបាត់ដំបង លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង បានបន្តធ្វើវគ្គបណ្តុះបណ្តាលស្តីពី៖ “កិច្ចការពារកុមារ និងការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងការរំលោភបំពាន - Training on Child Protection and Identification of Human Trafficking and Abuse” សម្រាប់ក្រុមទី២។ សិក្ខាកាមបានស្វែងយល់អំពីរបៀបសម្ភាសន៍ជនចំណាកស្រុកដែលត្រឡប់មកវិញ ដើម្បីកំណត់ថាតើពួកគេត្រូវបានរងគ្រោះដោយអំពើជួញដូរ ឬអត់។ វគ្គបណ្តុះបណ្តាលនេះក៏បានរួមបញ្ចូលនូវបច្ចេកទេសសម្រាប់ធ្វើបទសម្ភាសន៍ដល់កុមារផងដែរ។ បន្ទាប់ពីបញ្ចប់វគ្គបណ្តុះបណ្តាលនេះ មន្ត្រីជួរមុខទាំងនេះ នឹងត្រូវបានទទួលស្គាល់ ដើម្បីដឹកនាំដំណើរការកំណត់អត្តសញ្ញាណជនរងគ្រោះ។ វគ្គបណ្តុះបណ្តាលនេះកើតឡើង ក្រោមកិច្ចសហការរវាង អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាមួយ ក្រសួងសុខាភិបាល ដោយមានជំនួយឧបត្ថម្ភពីសហភាពអឺរ៉ុប (EU) តាមរយៈ អង្គការយូនីសេហ្វ គោលបំណង ផ្សព្វផ្សាយឱ្យបានកាន់តែទូលំទូលាយ និងពង្រឹងសមត្ថភាព ជូនមន្ត្រីអនុវត្តផ្ទាល់នៅមូលដ្ឋាន សរុបចំនួន ៤២រូប (ស្រី១៨រូប) អញ្ជើញពី ស្រុកត្រពាំងប្រាសាទ ស្រុកអន្លង់វែង នៃខេត្តឧត្តរមានជ័យ ស្រុកសាលាក្រៅ ស្រុកប៉ៃលិន នៃខេត្តប៉ៃលិន និង ស្រុកវាលវែង ស្រុកក្រវាញ នៃខេត្តពោធិ៍សាត់ ក្នុងចំណោមអ្នកចូលរួមសរុប ៥០រូប (ស្រី២២រូប) ក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះ ជាពិសេសស្ត្រី និងកុមារ ការបញ្ជូនករណីកុមាររងគ្រោះ និងងាយរងគ្រោះទៅកាន់សេវា សមស្រប ដើម្បីជានាការការពារ និងសុខមាលភាពរបស់កុមារដែលទទួលរងផលប៉ះពាល់ពីចំណាកស្រុក។

- **ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង លោកឧត្តមសេនីយ៍ត្រី អ៊ុន មាន ប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិ លោកស្រីវរសេនីយ៍ត្រី ថោង សុវត្ថិ អនុប្រធានក្រុមជំនួយកិច្ចការ បានអញ្ជើញចូលរួមសិក្ខាសាលាកែសម្រួលសៀវភៅគោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដើម្បីផ្តល់សេវាសមស្របលើកទី២ តាមរយៈប្រព័ន្ធវីដេអូពីចម្ងាយ ក្រោមអធិបតីភាពឯកឧត្តម ញឹក វណ្ណារ៉ា រដ្ឋលេខាធិការក្រសួងសង្គមកិច្ច និងជាអនុប្រធានក្រុមការងារការពារជនរងគ្រោះ គ.ជ.ប.ជ ក្រោមកិច្ចសហការរវាង អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ និងអង្គការ Asian ACT ដែលរៀបចំសិក្ខាសាលានេះឡើង។ អញ្ជើញចូលរួមមាន លោកជំទាវ សួស រដ្ឋាវី អនុរដ្ឋលេខាធិការ

ក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ លោកជំទាវ សឿ សុជាតា អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជនកីឡា ឯកឧត្តម សុន ពិសិដ្ឋ អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ លោកស្រី Nurul Qoiriah នាយកផ្នែកបរិយាប័ន្ន នៃកម្មវិធី Asian ACT ឯកឧត្តម លោកជំទាវ ជាអគ្គលេខាធិការរង ប្រធានលេខាធិការដ្ឋាន របស់អគ្គលេខាធិការដ្ឋាន គជបជ លោក លោកស្រី តំណាងស្ថាប័នពាក់ព័ន្ធ កិច្ចការយុត្តិធម៌ ការពារផ្លូវច្បាប់ អគ្គស្នងការដ្ឋាននគរបាលជាតិ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស ការពារអនីតិជន និងតំណាងពីអង្គការដៃគូរអភិវឌ្ឍ ដែលអនុវត្តការងារការពារសិទ្ធិជនរងគ្រោះ និងផ្តល់សេវាសង្គ្រោះបឋម តំណាងពីមណ្ឌលសំចត របស់នាយកដ្ឋានការពារជនរងគ្រោះ ក្រសួងសង្គមកិច្ច ។

- **ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២** លោកស្រី វរសេនីយ៍ត្រី ថោង សុវត្ថិ អនុប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិ បានអញ្ជើញចូលរួមប្រជុំតាមប្រព័ន្ធវីដេអូអនឡាញ ស្តីពីការត្រៀមសម្រាប់កិច្ចប្រជុំទ្វេភាគី រវាងរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលថៃ ដែលអញ្ជើញដឹកនាំកិច្ចប្រជុំដោយ **លោកជំទាវ ជូ ប៊ុនអេង** នៅបន្ទប់ប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ អញ្ជើញចូលរួមពី ឯកឧត្តម ជារដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច លោកជំទាវ ឧត្តមសេនីយ៍ឯកវេជ្ជ. ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ លោកជំទាវ នាយឧត្តមសេនីយ យក់ សុខា អគ្គស្នងការរងនគរបាលជាតិ និងជាអនុប្រធានក្រុមការងារអនុវត្តច្បាប់ គ.ជ.ប.ជ ឯកឧត្តម ជាអគ្គលេខាធិការរង លោក លោកស្រីតំណាងមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ មានក្រសួងយុត្តិធម៌ ក្រសួងការបរទេស ក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រធានលេខាធិការដ្ឋាន មន្ត្រីរបស់លេខាធិការដ្ឋាន អនុប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិ គ.ជ.ប.ជ តំណាងអង្គការយុត្តិធម៌អន្តជាតិ (IJM) តំណាងពីអង្គការអន្តរជាតិអាយអូអឹម (IOM) តំណាងអង្គការដៃគូអន្តជាតិ ដែលជាអ្នកសម្របសម្រួលកិច្ចការងារ រវាងភាគីទាំងពីរ កម្ពុជា ថៃ ។

- **ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង និងលោកឧត្តមសេនីយ៍ត្រី អិ ុន មាន ប្រធានក្រុមជំនួយកិច្ចការ សហប្រតិបត្តិការជាតិ និងអន្តរជាតិ បានអញ្ជើញចូលរួមពិធីចុះហត្ថលេខាលើអនុស្សារណៈ នៃការយោគយល់រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការវីនរ៉ក់អន្តរជាតិ ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ។ អញ្ជើញចូលរួមក្នុងកម្មវិធីមាន លោកជំទាវ ឧ.ឯក ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ លោក ម៉ាក ថាយល័រ ប្រធានគម្រោង CTIP តំណាងអង្គការវីនរ៉ក់ និងសហការី ឯកឧត្តម លោកជំទាវ ជាអគ្គលេខាធិការរង ទទួលបន្ទុកការងារ ក្រុមជំនួយកិច្ចការទាំង៦ ប្រធានលេខាធិការដ្ឋាន។ អនុស្សរណៈ នៃការយោគយល់នេះ មានគោលបំណង បង្កើនកិច្ចសហប្រតិបត្តិការរវាង គ.ជ.ប.ជ និងអង្គការវីនរ៉ក់អន្តរជាតិ តាមរយៈCTIP ដើម្បីរួមចំណែកលើកកម្ពស់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងបង្កើនប្រសិទ្ធភាពវិធានការ ប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា។

ខ.២-ការងារចងក្រងព័ត៌មានតាមគេហទំព័រសារព័ត៌មាននានា (មានឆ្ងាប់ក្នុងឧបសម្ព័ន្ធ)

- គ្រោះថ្នាក់ ឬហានិភ័យការងារក្នុងប្រទេសគោលដៅ
  - ឧបទ្ទវហេតុ ០០ នាក់
  - ពលករសរុប ០០ នាក់
- ប្រព្រឹត្តបទល្មើសនៅនឹងកន្លែង
  - ចាប់ខ្លួន ០០ នាក់
  - ពលករសរុប ០០ នាក់
- ពលកររួចទោសពីពន្ធនាគារ
  - ពលករសរុប ០០ នាក់
- ពលករចំណាកស្រុកខុសច្បាប់
  - បញ្ជូនត្រឡប់ **២៥៥ នាក់**
  - ចាប់ខ្លួន **១ នាក់**
  - ពលករសរុប **២៥៦ នាក់**

គ-ទិសដៅបន្ត

- រៀបចំវគ្គបណ្តុះបណ្តាលបន្តស្តីពី៖ "កិច្ចការពារកុមារ និងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការរំលោភបំពាន" នៅខេត្តកោះកុង
- បង្កើតគ្រុបតេឡេក្រាមក្រុមការងារព័ត៌មានថ្មី និងរៀបចំតារាងកាលវិភាគបណ្តុះបណ្តាល

ថ្ងៃ ខែ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០២២

**ប្រធាន**

**ក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិ**